# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧២ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការកំណត់គោលការណ៍គ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានខ្សាច់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៤០៤ អនក្រ.តត ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលសមាសភាពនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានប្រគល់ភារកិច្ចជូនក្រសួងរ៉ែ និងថាមពល ជាអ្នកចេញអាជ្ញាបណ្ណនិងទទួលខុសត្រូវគ្រប់បែបយ៉ាងលើការធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទ ដោយគិតចាប់ពីពេលដាក់ពាក្យស្នើសុំរហូតដល់ការចេញអាជ្ញាបណ្ណ។ រាល់អាជ្ញាបណ្ណទាំងអស់ ក្រសួងរ៉ែ និងថាមពលត្រូវចម្លងជូនក្រសួង ស្ថាប័ន ពាក់ព័ន្ធ។

**ប្រការ២ .-**

ការផ្ដល់អាជ្ញាបណ្ណអាជីវកម្មខ្សាច់គ្រប់ប្រភេទ ត្រូវអនុវត្តចំពោះតំបន់ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងផ្អែកតាមលទ្ធផលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ប្រការ៣ .-**

ក្រសួងធនធានទឹក និងឧតុនិយម ដោយសហការជាមួយក្រសួងរ៉ែ និងថាមពល ត្រូវកំណត់តំបន់ធនធានខ្សាច់ជា ៣(បី)តំបន់ ដោយផ្អែកលើលទ្ធផលនៃការសិក្សាលើជលវិទ្យានិងជលគតិ ដូចខាងក្រោម៖

១- តំបន់ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្ម។

២- តំបន់ដែលតម្រូវឱ្យមានការអនុញ្ញាតតាមការស្នើសុំពិសេស។

៣- តំបន់ដែលពុំអនុញ្ញាតឱ្យធ្វើអាជីវកម្ម។

តំបន់ទាំង៣(បី)ខាងលើ ត្រូវមាននិយាមការឱ្យបានច្បាស់លាស់។

**ប្រការ៤ ._**

ក្រសួងបរិស្ថាន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានការចូលរួមពីក្រសួងរ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងធនធានទឹក និងឧតុនិយម។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើឡើងដោយគោរពតាមបទដ្ឋានបច្ចេកទេស និងត្រូវកំណត់រយៈពេលអតិបរមានៃការផ្តល់សេវានិងតម្លៃសេវាឱ្យបានសមរម្យ។

**ប្រការ៥ ._**

អាជ្ញាបណ្ណធ្វើអាជីវកម្មខ្សាច់ ត្រូវមានសុពលភាពកំណត់រយៈពេល២(ពីរ)ឆ្នាំ និងពុំអនុញ្ញាតឱ្យចេញអាជ្ញាបណ្ណបណ្តោះអាសន្ន ជាដាច់ខាត។

**ប្រការ៦ ._**

ក្រសួងរ៉ែ និងថាមពល ត្រូវរៀបចំឱ្យមានយន្តការចែករំលែកព័ត៌មាន និងយន្តការឆ្លើយតបបន្ទាន់ចំពោះការរកឃើញការបូមខ្សាច់អនាធិបតេយ្យ ខុសពេលវេលា និងខុសពីការកំណត់ក្នុងអាជ្ញាបណ្ណ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ អាចរាយការណ៍អំពីការបូមខ្សាច់អនាធិបតេយ្យមកក្រសួងរ៉ែ និងថាមពលគ្រប់ពេលវេលា។

**ប្រការ៧ ._**

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ អនុវត្តភារកិច្ចរបស់ខ្លួន ក្នុងការត្រួតពិនិត្យនិងតាមដានការធ្វើអាជីវកម្មធនធានខ្សាច់។ ក្នុងករណីមានភាពអនាធិបតេយ្យឬការបូមខ្សាច់ខុសបច្ចេកទេស គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ផ្តល់អនុសាសន៍ក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីក្រសួងរ៉ែ និងថាមពល ចាត់វិធានការជាបន្ទាន់។

**ប្រការ៨ ._**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២០ សសរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកំណត់គោលការណ៍ធ្វើអាជីវកម្មខ្សាច់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ